**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៣៦០.....សហវ.ប្រក.ន.អគ

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ក្នុងការសម្របសម្រួល និងដោះស្រាយវិវាទពាក់ព័ន្ធសំណង់និងអចលនទ្រព្យ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- បានឃើញប្រកាសលេខ ០០៨ អសហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## **សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើត "គណៈកម្មការអន្តរក្រសួងក្នុងការសម្របសម្រួល និងដោះស្រាយវិវាទពាក់ព័ន្ធសំណង់និងអចលនទ្រព្យ" ដែលសរសេរជាអក្សរកាត់ថា "**គ.ស.ស.អ.**" ដើម្បីដឹកនាំ និងសម្របសម្រួល និងដោះស្រាយវិវាទពាក់ព័ន្ធសំណង់និងអចលនទ្រព្យ។ **គ.ស.ស.អ.** មានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១- ឯកឧត្តម **ជូ ចណ្ណា:** | អគ្គនាយក នៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ | ប្រធាន |
| ២- ឯកឧត្តម **យឹម ផារ៉ូត** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ | អនុប្រធាន |



N

| | | |
|---|---|---|
| ៣- ឯកឧត្តម **ឆាន់ សុវុទ្ធផល** | អគ្គនាយក នៃអគ្គនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤- ឯកឧត្តម **សួន សុផា** | អគ្គនាយក នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥- ឯកឧត្តម **សួស ច្រាផ្លា** | អគ្គនាយករងទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត នៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៦- ឯកឧត្តម **ម៉ិញ ឈានកុសល** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- ឯកឧត្តម **សុខ ពេញវុទ្ធ** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ៨- លោក **គិត សុវណ្ណារិទ្ធ** | អគ្គនាយកត្រួតពិនិត្យ នៃធនាគារជាតិ នៃកម្ពុជា | សមាជិក |
| ៩- លោកស្រី **ហេង ច័ន្ទសុតា** | អគ្គនាយករង នៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ | សមាជិក |
| ១០- លោក **អេង រតនា** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១១- លោក **លន់ សំអុល** | ប្រធាននាយកដ្ឋានត្រួតពិនិត្យ១ នៃធនាគារជាតិ នៃកម្ពុជា | សមាជិក |
| ១២- លោក **ម៉ៅ ពៅ** | ប្រធាននាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណ និងកិច្ចការគតិយុត្ត នៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ | លេខាធិការ។ |

**ប្រការ២.-**

**គ.ស.ស.អ.** មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួលនិងដោះស្រាយលើករណីវិវាទ ឬបណ្តឹងតវ៉ា ឬសំណើសុំអន្តរាគមន៍របស់ភាគីវិវាទដែលជាបញ្ហាប្រឈម និងអាចបង្កភាពចលាចល ពាក់ព័ន្ធនឹងសំណង់និងអចលនទ្រព្យនៃគម្រោងអភិវឌ្ឍអចលនវត្ថុ
- ដាក់ចេញនូវវិធានការចាំបាច់សមស្របលើប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធក្នុងករណីរកឃើញថាមានពិរុទ្ធភាពក្នុងការប្រកបអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ដោយបង្កចលាចល ឬអប្រក្រតីភាព ឬមិនគោរពតាមបទប្បញ្ញត្តិគតិយុត្តជាធរមានពាក់ព័ន្ធ
- លើកសំណើ និងវិធានការដំណោះស្រាយជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឬប្រមុខរាជរដ្ឋាភិបាល ក្នុងករណីចាំបាច់
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារនៃករណីវិវាទជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



ꝛ

- បំពេញការងារផ្សេងទៀតតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារប្រគល់ជូន។

**ប្រការ៣.–**

អនុប្រធាន សមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ស.ស.អ.**។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានអាចដឹកនាំកិច្ចប្រជុំជំនួស តាមការផ្ទេរសិទ្ធិរបស់ប្រធាន។ ចំពោះសមាជិកអវត្តមានត្រូវជូនដំណឹងនិងចាត់តំណាងចូលរួមជំនួស។

**ប្រការ៤.–**

**គ.ស.ស.អ.** មានសិទ្ធិស្នើសុំកិច្ចសម្របសម្រួល និងសហប្រតិបត្តិការពីក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក៏ដូចជាវិស័យឯកជនផងដែរ។

**ប្រការ៥.–**

**គ.ស.ស.អ.** ប្រើប្រាស់ត្រារបស់និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំសម្រាប់ការបំពេញការងាររបស់ខ្លួន។

**ប្រការ៦.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.–**

នាយកខុទ្ទកាល័យ អគ្គនាយក នៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៩កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ដូចប្រការ១ និងប្រការ៧ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ